ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៣ លេខ ០៣ សប្តាហ៍ទី ១ ថ្ងៃទី ០៨ ខែមករា ឆ្នាំ ២០១៣

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(**ត្រូវបង់តម្លៃជាវជាមុន**)

មាតិកា

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

p

មាតិកា

I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៩.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៧៣ ស្តីពី ការតែងតាំងឯកឧត្តម **ទ៉ាន់ ដារ៉ា** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១២១

២០.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៧៧ ស្តីពី ការដំឡើងថ្នាក់ តាមសញ្ញាបត្រ ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការ ចំនួន ០១ រូប ១២២

២០.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៧៨ ស្តីពី ការដាក់មន្ត្រីរាជការ ឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ចំនួន ០៩ រូប និង មន្ត្រីរាជការឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល ចំនួន ០៤ រូប ឱ្យចូលនិវត្តន៍ ១២៣

២០.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៧៩ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ជូនមន្ត្រីរាជការ របស់ក្រសួង ស្ថាប័ន ចំនួន ១៧ រូប ១២៦

២០.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៨០ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ជូនមន្ត្រីរាជការ ចំនួន ៧៩ រូប ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១២៩

២៤.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៨២ ស្តីពី ការដំឡើងថ្នាក់ ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី តាមកម្រិតសញ្ញាប័ត្រ ជូនមន្ត្រីរាជការ ចំនួន ០៤ រូប ១៣៣

២៤.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៨៣ ស្តីពីការប្រោសព្រះរាជទាន នូវ គ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក និង លោកស្រី ចំនួន ៤៧ រូប ១៣៤

២៤.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៨៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០២ រូប ១៣៦

២៤.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៨៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឯកឧត្តម និង លោកជំទាវ ជាសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន ០៦ រូប ១៣៧

២៥.១២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៩០ ស្តីពី ការកាត់ផ្ទៃដីទំហំ ៨៩.០០១៥ ហិកតា នៅស្រុកទឹកឈូ ខេត្តកំពត ចេញពីឧទ្យានជាតិបូកគោ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ៨២ ១៣៨

II. រាជរដ្ឋាភិបាល

អនុក្រឹត្យ

២៤.១២.២០១២ - អនុក្រឹត្យលេខ ២៦២ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៧៩២ ហិកតា នៅស្រុកតំបែរ ខេត្តកំពង់ចាម កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន សាម លីញ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ១៣៩

២៤.១២.២០១២ - អនុក្រឹត្យលេខ ២៦៣ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៧១១ ហិកតា នៅស្រុកតំបែរ ខេត្តកំពង់ចាម កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ និង ពីព្រៃសម្បទានក្រុមហ៊ុន សាម លីញ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ១៤២

២៤.១២.២០១២ - អនុក្រឹត្យលេខ ២៦៤ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៨៥៥ ហិកតា នៅស្រុកតំបែរ ខេត្តកំពង់ចាម កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន សាម លីញ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើ ប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ១៤៥

២៤.១២.២០១២ - អនុក្រឹត្យលេខ ២៦៥ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៤.៦៩៨ ហិកតា ដែលក្នុងនោះកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន កាសូទីម ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និង កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ដូវទៀង ខេមបូឌា ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ដូវទៀង ក្រចេះ ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ច័ន្ទសុភា ព្រមទាំងស្នើសុំប្រទានកម្ម ជំនួសដីសម្បទានសង្គមកិច្ច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ និង ការផ្តល់សិទ្ធិលើក្បាលដី ១៤៨

២៦.១២.២០១២ - អនុក្រឹត្យលេខ ២៦៦ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ២៩៥,៣៧៩៥ ហិកតា នៅស្រុកទឹកឈូរ ខេត្តកំពត ដែលក្នុងនោះ កាត់ចេញពីឧទ្យានជាតិបូកគោ និង ពីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៥២

p

គ

២៦-១២-២០១២-អនុក្រឹត្យលេខ ២៦៧ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ២.៨៨៩.៧៧ ហិកតា នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ចេញពីព្រៃសម្បទានក្រុមហ៊ុន ឃ្វីសាគរ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៥៥

២៦-១២-២០១២-អនុក្រឹត្យលេខ ២៦៨ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៦៥១.២១ ហិកតា នៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៥៨

២៦-១២-២០១២-អនុក្រឹត្យលេខ ២៦៩ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ១.៩៩៨ ហិកតា នៅស្រុករុក្ខគិរី ខេត្តបាត់ដំបង ចេញពីព្រៃសម្បទានក្រុមហ៊ុន ឃ្វីសាគរ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៦២

២៦-១២-២០១២-អនុក្រឹត្យលេខ ២៧០ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៧.៥០០ ហិកតា នៅស្រុកកំរៀង ខេត្តបាត់ដំបង ក្នុងនោះកាត់ចេញពីដីរបស់រដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន លាង ហួហុង និង អភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្ម និង កែច្នៃ) និង ពីព្រៃសម្បទានព្រៃឫស្សី ក្រុមហ៊ុន ភាពីម៉ិច ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកជាដីភ្នំ និង ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ១៦៥

២៦-១២-២០១២-អនុក្រឹត្យលេខ ២៧១ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១៧០

២៧-១២-២០១២-អនុក្រឹត្យលេខ ២៧២ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១៧២

៣១-១២-២០១២-អនុក្រឹត្យលេខ ២៧៣ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១៧៤

៣១-១២-២០១២-អនុក្រឹត្យលេខ ២៧៤ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១៧៦

៣១-១២-២០១២-អនុក្រឹត្យលេខ ២៧៥ អនក្រ.បក ស្តីពី ការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ១៧៨

៣១-១២-២០១២-អនុក្រឹត្យលេខ ២៧៦ អនក្រ.បក ស្តីពី ការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ១៨០

៣១-១២-២០១២-អនុក្រឹត្យលេខ ២៧៧ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១៨២

៣១-១២-២០១២-អនុក្រឹត្យលេខ ២៧៨ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១៨៤

០៣-១១-២០១៤-អនុក្រឹត្យលេខ **២៣១១** ដល់អនុក្រឹត្យលេខ **២៣៨៥** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៨៦

III~ការងារបណ្ណាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៤៨៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេ ប្រីហ្វេសិនណល អីខោនថីន** ២២១

២៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៤៨៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ម៉ាស្ទ័រ អាគ្រ្គោរថេត (ខេមបូឌា)** ២២៣

២៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៤៨៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **វីន អាគ្រ្គោ ម៉ាស៊ីនេរី** ២២៥

២៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៤៨៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **សាំង ឈុនលី** ២២៧

២៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៤៩០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេ អេន អិម អាគ្រ្គោ** ២២៩

២៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៤៩១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **គ្រ្គីន អូតូម៉ូធីវ អ៊ីមផត អិចផត** ២៣១

២៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៤៩២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉ាដឹស ម៉ាឃីត (ខេមបូឌា)** ២៣៣

២៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៤៩៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខ្មែរ ពស្ទូធា** ២៣៥

២៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៥០១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **គ្រី-អិម (ខេមបូឌា)** ២៣៧

២៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤៥០៦ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **គំពង់ស្ពឺ ស៊ូហ្គើរ** ២៣៩

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ម៉ាន់ ដារ៉ា** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខៈ [illegible] ច.ល

[illegible]

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២

[illegible] រដ្ឋាភិបាល

ស៊យ សុខា

[illegible]. ១២១២.១០៧៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងថ្នាក់តាមសញ្ញាបត្រក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការ ៖

ល.រ	គោត្តនាម និងនាម	ភេទ	ឋានន្តរស័ក្តិ ថ្នាក់ចាស់	ឋានន្តរស័ក្តិ ថ្នាក់ថ្មី
១	ប្រាក់ សុផាន់	ប	ពី ឧត្តមមន្ត្រី ថ្នាក់លេខ ២	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ១

មាត្រា ២ : បៀវត្សមូលដ្ឋានរបស់ សាមីខ្លួន ត្រូវបានអនុវត្តគិតចាប់ពីថ្ងៃចេញព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចាស. ១២.១២.១០៧៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១២

លេខ: ១០៣៧ ច.ល

សម្រាប់ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២

អគ្គលេខាធិការ [illegible] រាជរដ្ឋាភិបាល

[illegible]

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានក្ខមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដាក់មន្ត្រីរាជការឋានន្តរសក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ចំនួន ០៦ រូប ឱ្យចូលនិវត្តន៍ដោយនៅរក្សាមុខតំណែងនយោបាយដដែល រហូតមានការសម្រេចជាថ្មីពីរាជរដ្ឋាភិបាល៖

ល.រ	គោត្តនាម និងនាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	មុខតំណែង	ឋានន្តរសក្តិ និងថ្នាក់	ថ្ងៃខែឆ្នាំចូលនិវត្តន៍
ក្រសួងផែនការ						
១	**ហ៊ឺ តាំងអេង**	ប	០៣-០២-១៩៥៣	រដ្ឋលេខាធិការ	ឧត្តមមន្ត្រី ថ្នាក់លេខ ១	០១-០៣-២០១៣
ក្រសួងធម្មការ និងសាសនា						
១	**ឡោក ផន**	ប	១០-០២-១៩៥៣	រដ្ឋលេខាធិការ	ឧត្តមមន្ត្រី ថ្នាក់លេខ ១	០១-០៣-២០១៣
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់						
១	**សួន ស៊ីផាត**	ប	០៥-០៤-១៩៥២	ទីប្រឹក្សាក្រសួង ថ្នាក់ស្មើ អនុរដ្ឋលេខាធិការ	ឧត្តមមន្ត្រី ថ្នាក់លេខ ៤	០១-០៥-២០១២
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍						
១	**គួច គី**	ប	១៣-០៧-១៩៥៣	រដ្ឋលេខាធិការ	ឧត្តមមន្ត្រី ថ្នាក់លេខ ៦	០១-០៨-២០១៣
២	**កែវ ឧត្តរិន**	ប	២៤-១០-១៩៥៣	អនុរដ្ឋលេខាធិការ	ឧត្តមមន្ត្រី ថ្នាក់លេខ ៦	០១-១១-២០១៣
ក្រសួងពាណិជ្ជកម្ម						
១	**មាន សុភា**	ប	០១-០៣-១៩៥៣	ទីប្រឹក្សាក្រសួង ថ្នាក់ស្មើ អនុរដ្ឋលេខាធិការ	ឧត្តមមន្ត្រី ថ្នាក់លេខ ៦	០១-០៤-២០១៣

មាត្រា ២ : ដាក់មន្ត្រីរាជការឋានន្តរសក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ចំនួន ០៣ រូប ឱ្យចូលនិវត្តន៍:

ល.រ	គោត្តនាម និងនាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	មុខតំណែង	ឋានន្តរសក្តិ និងថ្នាក់	ថ្ងៃខែឆ្នាំចូលនិវត្តន៍
ក្រសួងផែនការ						
១	**សន ស៊ីថន**	ប	០១-០២-១៩៥៣	អគ្គនាយក	ឧត្តមមន្ត្រី ថ្នាក់លេខ ១	០១-០៣-២០១៣
[illegible]	**[illegible] ណារិន**	ប	១០-០៣-១៩៥៣	មន្ត្រីគ្រប់គ្រងរដ្ឋបាល	ឧត្តមមន្ត្រី ថ្នាក់លេខ ៦	០១-០៤-២០១៣
ក្រសួង[illegible] និងដឹកជញ្ជូន						
[illegible]	**អ៊ឹង ឈុនហួរ**	ប	១៥-០៥-១៩៥៣	អគ្គនាយក	ឧត្តមមន្ត្រី ថ្នាក់លេខ ១	០១-០៦-២០១៣

មាត្រា ៣ : ដាក់មន្ត្រីរាជការឋានន្តរសក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់របស់ក្រសួងការសុខាភិបាលចំនួន ០៤ រូប ឱ្យចូលនិវត្តន៍ :

ល.រ	គោត្តនាម និង នាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	មុខតំណែង	ឋានន្តរសក្តិ និង ថ្នាក់	ថ្ងៃខែឆ្នាំចូលនិវត្តន៍
១	**តៅ ខាសនា**	ប	៣១-១២-១៩៥៣	សាស្ត្រាចារ្យ មហាបរិញ្ញា	មន្ត្រីសុខាភិបាល ជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣	០១-០១-២០១៤
២	**នង គីមនី**	ប	១៤-១២-១៩៥៣	សាស្ត្រាចារ្យ មហាបរិញ្ញា	មន្ត្រីសុខាភិបាល ជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣	០១-០១-២០១៤
៣	**ចាន់ រី**	ស	២៥-០២-១៩៥៣	សាស្ត្រាចារ្យ មហាបរិញ្ញា	មន្ត្រីសុខាភិបាល ជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣	០១-០៣-២០១៣
៤	**ភាវ ស៊ុនបុណ្ណាត**	ប	១៩-០១-១៩៥៣	សាស្ត្រាចារ្យ មហាបរិញ្ញា	មន្ត្រីសុខាភិបាល ជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣	០១-០២-២០១៣

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៥ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នសរកត. ១២១២.១០៩៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១២

លេខៈ១០៤២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ២០១២

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊ុយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ប្រកាសបង្គាប់

មាត្រា ១ : តាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ១០ រូប ទៅក្នុងឋានន្តរសក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល :

ល.រ	នាម និង គោត្តនាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	ឋានន្តរសក្តិ	ថ្នាក់
តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១២ តទៅ					
១	**តូច ពលពណ្ណា**	ស	០៥/០៧/១៩៦៩	អនុមន្ត្រី	ថ្នាក់លេខ ១៣
តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១២ តទៅ					
២	**ឌុត អ៊ិនច័ណរ៉ា**	ប	១០/០៤/១៩៧៩	អនុមន្ត្រី	ថ្នាក់លេខ ១៣
តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ តទៅ					
៣	**ជា មុនីរ័ត្ន**	ប	០២/០២/១៩៨៥	អនុមន្ត្រី	ថ្នាក់លេខ ១៤
៤	**ចាន់ ស៊ីមង្គល**	ប	១២/០២/១៩៨១	អនុមន្ត្រី	ថ្នាក់លេខ ១៤
៥	**យឹម សុគី**	ស	១៥/០៤/១៩៨១	អនុមន្ត្រី	ថ្នាក់លេខ ១៤
៦	**សោម កែវចមរោគ**	ស	៣០/០៨/១៩៨៧	អនុមន្ត្រី	ថ្នាក់លេខ ១៤
៧	**ឈឹន សាឈីន**	ប	០១/០១/១៩៨២	អនុមន្ត្រី	ថ្នាក់លេខ ១៤
៨	**អ៊ូ គញ្ញា**	ស	០៨/០៩/១៩៨៣	អនុមន្ត្រី	ថ្នាក់លេខ ១៤
៩	**ស៊ាន ចិន្ដូ**	ប	០១/០៤/១៩៨៦	អនុមន្ត្រី	ថ្នាក់លេខ ១៤
១០	**សុខ សប្បាយណា**	ប	២៨/០២/១៩៨៨	អនុមន្ត្រី	ថ្នាក់លេខ ១៤

មាត្រា ២ : តាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការរបស់ក្រសួងធម្មការ និងសាសនា ចំនួន ០២ រូប ទៅក្នុង ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តម នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម :

ល.រ	នាម និង គោត្តនាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	ឋានន្តរសក្តិ	ថ្នាក់
តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១០ តទៅ					
១	**អែម ឧត្តម**	ប	០៨/០៤/១៩៧៧	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១០ តទៅ					
២	**ផាន់ ឡឿន**	ប	១៣/០១/១៩៧២	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤

មាត្រា ៣ : តាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការ ចំនួន ០៥ រូប ទៅក្នុងឋានន្តរសក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល :

ល.រ	នាម និង គោត្តនាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	ឋានន្តរសក្តិ	ថ្នាក់
តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ តទៅ					
[illegible]	**ស៊ិន ឡាលីន**	ប	០៦/០៧/១៩៨១	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៤
២	**[illegible] សេរីវឌ្ឍនា**	ប	២៤/០៩/១៩៨១	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៤
[illegible]	**[illegible] មុំ**	ស	១២/១២/១៩៧៩	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE ROYAL
ព្រះបរមរាជវាំង

តាំងស៊ីបចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១២ តទៅ					
៤	**ស៊ឹម សុខចាន់**	ប	២៦/១១/១៩៧៩	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៣
៥	**ហ៊ីយ សុគ័គ**	ស	០៥/០៤/១៩៨៤	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៣

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៥ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១២

[illegible]. ១៤.១២.១០៤៩

លេខ: ១០៤៣ ប.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១២

អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការចំនួន ៧៩ រូប ទៅក្នុងឋានន្តរសក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១២ តទៅ:

ល.រ	នាម និង គោត្តនាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	ឋានន្តរសក្តិ	ថ្នាក់
១	សុខ លក្ខស្មី	ស្រី	៣០/១២/១៩៨៥	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២	ប៉ាង សិទ្ធី	ប្រុស	០៦/០២/១៩៨៥	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣	[illegible] ម៉ុងដែន	ប្រុស	០២/១២/១៩៨០	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤	សុខ ឡាដេត	ប្រុស	២៣/០២/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE du PALAIS ROYAL

៥	អ៊ុក ចាន់សុភាព	ស្រី	១៤/០១/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦	ឈិន ទេពីរក្ស	ប្រុស	១៣/១១/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧	ឡូ លីគាន	ស្រី	១៧/១១/១៩៨៤	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨	អ៊ីង គីមស្រៀង	ប្រុស	២៨/០៩/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៩	គុជ ចាន់ស្រស់	ប្រុស	២២/០១/១៩៨៤	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១០	ឃឹម រដ្ឋា	ប្រុស	២២/០៦/១៩៨០	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១១	ខណ្ឌថន មករា	ប្រុស	១៤/០១/១៩៨៤	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១២	ចេន សុផានិត	ប្រុស	២៤/០៨/១៩៨៤	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៣	ផាន់ ម៉េងហួរ	ប្រុស	០៨/០៣/១៩៨៥	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៤	ច័ន្ទ តារ៉ា	ប្រុស	០២/០១/១៩៨៤	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥	ជួន ច័ន្ទសោភា	ប្រុស	១៥/១២/១៩៨០	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦	សាយ មករា	ប្រុស	១០/០១/១៩៨៥	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៧	អៀង សុផាត	ប្រុស	១០/០៤/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៨	សុវណ្ណ សិរីវឌ្ឍន៍	ប្រុស	០៧/០១/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៩	ឃឹម ចាន់ដារ:	ប្រុស	២៥/១២/១៩៨០	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២០	ស៊ាន សង្ហា	ប្រុស	០១/១១/១៩៨០	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២១	ហែម ឥត្ថី	ប្រុស	០៧/០៤/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២២	លេង សុភាព	ស្រី	០៣/១២/១៩៧៩	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៣	ស៊ីន តុលា	ប្រុស	០៨/១០/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៤	យ៉េតនី តារ៉ាន់	ប្រុស	០៤/០៥/១៩៨៤	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៥	ហ៊ាន់ ចាន់ថន	ប្រុស	១៥/១០/១៩៨១	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៦	សាំង សុធី	ប្រុស	០១/០៩/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៧	ធន់ រិទ្ធី	ប្រុស	១៦/១២/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៨	ឡាយ សារិទ្ធិ	ប្រុស	០៩/១២/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៩	ឱ ដាលីស	ស្រី	២២/០៤/១៩៨១	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣០	ទ្រឹង សោភ័ណ	ប្រុស	១៦/០៥/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣១	ជៀម គារឧត្ត	ប្រុស	០៦/០១/១៩៨៥	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣២	សុខ សុវាសី	ប្រុស	២៨/០៥/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣៣	អាន ភក្តិថ្នា	ស្រី	០៨/០៦/១៩៨០	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣៤	[illegible]ង ចារិទ្ធ	ប្រុស	០១/០១/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
[illegible]	[illegible] ពុទ្ធី	ប្រុស	៣១/១០/១៩៧៩	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
[illegible]	[illegible] សុខជា	ប្រុស	២៤/០៤/១៩៨១	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

៣៧	ឡុន រតនា	ប្រុស	១២/០៦/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣៨	ស៊ឹម សុវណ្ណរិទ្ធ	ប្រុស	២៧/១០/១៩៨៤	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣៩	សេង សុធាន	ប្រុស	០៥/០៩/១៩៨០	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤០	ទី ហ៊ាង	ស្រី	០៦/០៧/១៩៨០	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤១	ឃឹម សុខរតនា	ប្រុស	១៤/០៣/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤២	ឃឹម កណ្ណិកា	ស្រី	០៦/០៦/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤៣	យូ ស៊ីថាន	ប្រុស	៣០/១០/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤៤	អ៊ុយ ពិសី	ស្រី	២៧/០៤/១៩៨៥	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤៥	ម៉ូ ម៉ុណ្ណា	ប្រុស	០៤/០៩/១៩៨៤	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤៦	ឈាង ហ៊ន់	ប្រុស	០១/០៣/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤៧	ឃិន ច័ន្ទសិរី	ស្រី	១៥/០៥/១៩៨៥	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤៨	ជា ដា	ប្រុស	០៨/១០/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤៩	អេន សុវណ្ណ	ប្រុស	០៥/១០/១៩៨១	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥០	ស្រី ផ្កា	ប្រុស	២៣/០៨/១៩៨០	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥១	ម៉ៅ ឌុំយ	ប្រុស	២៤/០១/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥២	ហ៊ាង ចន្ទរះ	ប្រុស	១១/១០/១៩៨១	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥៣	កៅ តាក់	ប្រុស	១៥/០៥/១៩៨៤	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥៤	គី សល់	ប្រុស	៣០/១០/១៩៨០	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥៥	ទៃ សុភ័ណ	ប្រុស	១០/១០/១៩៨៤	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥៦	លី គឹមសាន	ប្រុស	០១/០៨/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥៧	គូ សុភ័ក្រ	ប្រុស	០២/០៥/១៩៨១	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥៨	ឡុក ផាន់ណា	ប្រុស	១១/០៥/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥៩	តាំង សុលីដា	ស្រី	០៥/០៥/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦០	ហាក់ ចន្ទរះ	ប្រុស	១៧/០៧/១៩៨០	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦១	អ៊ុយ យុនម៉ុននាយ	ប្រុស	០៦/១១/១៩៧៩	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦២	ហួន គុណា	ប្រុស	១២/១០/១៩៨០	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦៣	ញ៉ែម សាវុធ	ប្រុស	១១/១០/១៩៨០	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦៤	ខែម រតនៈ	ប្រុស	២៨/០៤/១៩៨៤	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦៥	ជា បញ្ញា	ប្រុស	១៩/០៩/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦៦	[illegible] រុនស៊ីណារ៉េត	ប្រុស	០១/០១/១៩៨៧	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦៧	សេង ប៊ុនណារ៉ែន	ស្រី	០៤/០៨/១៩៨៤	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦៨	[illegible] រតនាសោភា	ស្រី	០១/០៧/១៩៨៦	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

p

៦៩	**សុត ចិន្តា**	ស្រី	២២/០៩/១៩៨១	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧០	**ហ៊ឹម ឡុងឌី**	ប្រុស	១០/០៦/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧១	**គុយ តុលា**	ប្រុស	០១/១០/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧២	**ហង្ស សំបូរពិសិដ្ឋ**	ប្រុស	០១/១០/១៩៨១	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧៣	**ឡាយ អ៊ូរ**	ប្រុស	២១/០៣/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧៤	**ស៊ុន សុឃុន**	ស្រី	០១/១០/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧៥	**គុយ ហុង**	ប្រុស	០២/០៨/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧៦	**លី វណ្ណា**	ប្រុស	១៧/០២/១៩៨៣	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧៧	**ជា កេណ្ឌាប្ញទ្ធិ**	ប្រុស	១០/១០/១៩៨១	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧៨	**ម៉ុន វឌ្ឍនៈ**	ប្រុស	២៥/១០/១៩៨២	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧៩	**សំអាត សុខប្រសើរ**	ស្រី	០៦/០៤/១៩៨៦	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចារ. ១២១២.១០៩០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១២

លេខ ១០៤៤ ប.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១២

អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី តាមកម្រិតសញ្ញាប័ត្រ ជូនមន្ត្រីរាជការចំនួន ០៤ រូប ៖

ល.រ	គោត្តនាម និងនាម	ភេទ	ថ្នាក់ចាស់	ថ្នាក់ថ្មី
១	អ៊ាង សុជល្វែក	ប	ថ្នាក់លេខ ៤	ថ្នាក់លេខ ៣
២	ឃឹម ស្រ៊ីជា	ប	ថ្នាក់លេខ ៤	ថ្នាក់លេខ ៣
៣	ប៉ុន ណារិទ្ធិ	ប	ថ្នាក់លេខ ៤	ថ្នាក់លេខ ៣
៤	សូ ណារ៉ូ	ប	ថ្នាក់លេខ ៥	ថ្នាក់លេខ ៤

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចរាច. ១២.១២.១០៥៦

បានឃើញ
លេខៈ ១០៥៦ ចល
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការ ... រាជរដ្ឋាភិបាល
សុខ សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៥៣

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម **នូ កេតិរិទ្ធិ**
២- ឯកឧត្តម **អ៊ុក រី**
៣- ឧកញ៉ា **ថៃ សេងឡុង**
៤- ឯកឧត្តម **ឌិន ម៉ាន់ដេន**
៥- ឯកឧត្តម **កែម គារាពន្យ**
៦- ឯកឧត្តម **ជុំ សំណាង**
៧- ឯកឧត្តម **ប៉ោ វណ្ណះ**
៨- លោក **ស៊ិន ញ៉ា**
៩- លោក **ផែ គា**
១០- លោក **មាស ម៉ាន់ថុន**
១១- លោក **សំ ដេត**
១២- លោក **សោម ផល្លី**

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- លោក **ទី សុខុន**
២- លោក **អ៊ុង សុវណ្ណរិទ្ធ**
៣- លោក **អ៊ុម ដារ៉ា**
៤- លោក **ជឹង គាងសេង**
៥- លោក **ទឹម គីមឡេង**
៦- លោក **យិន ហាន**

គ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម **គឹម សុវណ្ណ**
២- ឯកឧត្តម **លី សុខខេង**
៣- ឯកឧត្តម **ទិន ម៉ឹង**
៤- ឯកឧត្តម **ចាច់ វណ្ណះ**
៥- ឯកឧត្តម **ឆាង ពៅ**
៦- ឯកឧត្តម **សួស សុខុន**
៧- ឯកឧត្តម **ជួប ច័ន្ទ**
៨- ឯកឧត្តម **ស្រ៊ុន គុន្ធុល**
៩- លោក **អ៊ុង ទីរៈ**

ឃ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម **ឈិម សារ៉ាក់**
២- ឯកឧត្តម **ឈឹម គីមលាង**
៣- ឯកឧត្តម **សុខ លីនណា**
៤- លោក **លឹម ចិចិត្រ**

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

p

ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៖

១- លោក **ម៉ៅ ទូច**
២- លោក **គាត សុមនា**
៣- លោក **ប៉ាល់ សារិន**
៤- លោកស្រី **គា ម៉ាន់លី**
៥- លោក **ខូច ចន្ត្រា**
៦- លោក **មាស ផល្លី**
៧- លោក **សឹង សារិន**
៨- លោក **ពុធ ហាន**
៩- លោក **លឹម សុខា**
១០- លោក **ឌុល ស៊ីថុល**
១១- លោក **យឹម ម៉ុគុណា**
១២- លោក **សេន សុគា**
១៣- លោក **អ៊ុច រ៉េត**
១៤- លោក **សោ យឹម**
១៥- លោក **តន់ យូម**
១៦- លោកស្រី **ម៉ែន ច័ន្ទរស្មី**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.រកត.១២១២.១០៩៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១២

លេខ ១០៥០ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១២
[illegible] រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០២រូប មានគុណបំណាច់ខ្ពស់ ក្នុងការរួមចំណែកបរិច្ចាគធនធានចូលរួម កសាងសមិទ្ធផលនានា នៅវត្ត ឧត្តមគិរីបុប្ផតាសីលាគង្គា(ហៅវត្តជ្រុងថ្ម) ស្ថិតនៅឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍
- ឯកឧត្តម ស៊ាង ប៊ុនលាង

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា
- លោកជំទាវ ហ៊ុន ប៊ុនធឿន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible]-១២១២.១០៩៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១២

លេខ:១០៤៩ប.ល
[illegible]
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០១២
[illegible]រដ្ឋាភិបាល
[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម និងលោកជំទាវ ជាសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន ០៦រូប
ដែលមានស្នាដៃល្អ និងគុណបំណាច់ធំៗជាច្រើន ក្នុងការចូលរួមចំណែកកសាង
អភិវឌ្ឍន៍ប្រទេសជាតិ

នូវ

គ្រឿងឥស្សរិយយស ជាតូបការ :

១- ឯកឧត្តម ស៊្មើយ តែម

២- ឯកឧត្តម ឡាយ អ៊ុកសិទ្ធ

៣- ឯកឧត្តម ម៉េង ប៉ាត

៤- ឯកឧត្តម អន ស៊ឹ

៥- ឯកឧត្តម ប្រាក់ ចំរើន

៦- លោកជំទាវ តែម ម៉ាលី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១២១២.១០៩៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២

លេខ:១០៤៩ប.ល
[illegible]ចែក
រាជធានីភ្នំពេញ [illegible] ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៩០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ហូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: កាត់ផ្ទៃដីទំហំ ៨៩,០០១៥ ហិកតា នៅស្រុកទឹកឈូ ខេត្តកំពត ចេញពីឧទ្យានជាតិបូកគោ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ២ ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពការ. ១៤១៤. ១១០០

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២

លេខ ១០៤៧ប.ល
ដើម្បីចម្លងចែក
រាជធានី[illegible] ៧ [illegible] ឆ្នាំ២០១២
[illegible]រដ្ឋាភិបាល
សយ សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៦២ . អនក្រ.បក

អនុក្រឹត្យ
ស្តីពី

ការកាត់ដីសរុបទំហំ ៧៩២ ហិកតា នៅស្រុកតំបែរ ខេត្តកំពង់ចាម កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន សាម លីញ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

p

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២៤២១ លខកច ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីទំហំ ៧៩២ ហិកតា កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន សាម លីញ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិតាកែវ ឃុំសេដា ស្រុក តំបែរ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន២៧៨គ្រួសារដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិតាកែវ ឃុំសេដា ស្រុកតំបែរ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

p

មាត្រា ៤..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៦៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ៧១១ ហិកតា នៅស្រុកតំបែរ ខេត្តកំពង់ចាម
កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ និងពីព្រៃសម្បទានក្រុមហ៊ុន សាម លីញ
ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

p

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២៤២២ លខកច ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីទំហំ ៧១១ ហិកតា នៅស្រុកតំបែរ ខេត្តកំពង់ចាម កាត់ចេញពីគម្របព្រៃឈើ ២០០២ និងពីព្រៃសម្បទានក្រុមហ៊ុន សាម លីញ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិកកោះ ឃុំតំបែរ ស្រុកតំបែរ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៤៩ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិកកោះ ឃុំតំបែរ ស្រុកតំបែរ ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

p

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ . សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ២៧៤ . អនក្រ . បក

អនុក្រឹត្យ
ស្តីពី

ការកាត់ដីសរុបទំហំ ៨៥៥ ហិកតា នៅស្រុកតំបែរ ខេត្តកំពង់ចាម កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន សាម លីញ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ

p

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២៤២០ លខកច ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីទំហំ ៨៥៥ ហិកតា កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន សាម លីញ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិត្រពាំងរំដួល ឃុំតំបែរ ស្រុកតំបែរ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា ២.-

